**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខៈ......១៥៧..........ប្រ.ក.វវស

រាជធានីភ្នំពេញ, ថ្ងៃទី៣០....ខែឧសភា ឆ្នាំ ២០០៧

# ប្រ ក ា ស

## ស្តីពី

## តួនាទីភារកិច្ច និងរចនាសម្ព័ន្ធ

## របស់សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌

៣៧ ៣៧ ៣

## រដ្ឋមន្រ្តីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤.អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌

## ស ម្រ េ ច

**ប្រការ ១.-**

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ជាអង្គភាពមួយថ្នាក់ស្មើនាយកដ្ឋានស្ថិតក្រោមឱវាទផ្ទាល់របស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានភារកិច្ចធ្វើការបណ្តុះបណ្តាលមុខវិជ្ជាជំនាញចាំបាច់រួមមាន ៈ

-រៀបចំធ្វើវិក្រឹត្យការជូនចំពោះមន្ត្រីរាជការមុនពេលបញ្ចូលក្របខ័ណ្ឌ .

-ធ្វើសុក្រឹតការមន្ត្រីរាជការក្រសួង .

-រៀបរៀងកម្មវិធីសិក្សាស្របតាមការរៀបចំ ក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង .

-ទំនាក់ទំនង និងសហការជាមួយអង្គភាពចំណុះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ពាក់ព័ន្ធដល់ការបើកវគ្គ រៀបចំខ្លឹមសារសិក្សា ការបង្រៀន របៀបបង្រៀន វិធីសាស្ត្របង្រៀន និងជ្រើសរើសសាស្ត្រាចារ្យដែលត្រូវបង្រៀន .

-រៀបចំផែនការការងារ ផ្សព្វផ្សាយពត៌មាន បែបបទផ្សេងៗ និងសុំធនាគារលទ្ធផលដែលរំពឹងទុក .

-ចុះត្រួតពិនិត្យ វាយតម្លៃករិតយល់ដឹងមន្ត្រីរាជការដែលបានធ្វើ វិក្រឹត្យការ និងសុក្រឹតការរួចហើយ .

-ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន .

-ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលក្រសួងប្រគល់ជូន .

**ប្រការ ២.-**

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ដឹកនាំដោយនាយក( ថ្នាក់ស្មើប្រធាននាយកដ្ឋាន ) មួយរូប ទទួលខុសត្រូវរួម និងនាយករង ( ថ្នាក់ស្មើ អនុប្រធាននាយកដ្ឋាន ) មួយចំនួនជាជំនួយការ ។

**ប្រការ ៣.-**

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ មានការិយាល័យ ៤ គឺ :

១- ការិយាល័យ រដ្ឋបាល

២- ការិយាល័យ បណ្តុះបណ្តាល វិក្រឹត្យការ និងសុក្រឹតការ

៣- ការិយាល័យ គរុកោសល្យ

៤- ការិយាល័យ គ្រប់គ្រងឯកសារ

ការិយាល័យនីមួយ ៗ មានប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

អង្គការលេខ សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ជាឧបសម្ព័ន្ធ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ការិយាល័យនីមួយ ៗ មានភារកិច្ច :

១- ការិយាល័យ រដ្ឋបាល :

-គ្រប់គ្រងការងាររដ្ឋបាល.

-គ្រប់គ្រងការងារបុគ្គលិកនិងកិច្ចការសង្គម.

-គ្រប់គ្រងការងារ ហិរញ្ញកិច្ច សំភារៈបរិក្ខារ.

-គ្រប់គ្រងការងារ ពិធីការ អនាម័យ.

-គ្រប់គ្រងការងារ សន្តិសុខ.

២- ការិយាល័យ បណ្តុះបណ្តាល វិក្រឹត្យការ និងសុក្រឹតការ :

-ផ្សព្វផ្សាយពត៌មាន បែបបទក្នុងការ បណ្តុះបណ្តាលធ្វើ វិក្រឹត្យការ និង សុក្រឹតការ ដល់មន្ត្រីរាជការរបស់ក្រសួង .

-បើកវគ្គ បណ្តុះបណ្តាលមុខវិជ្ជាចាំបាច់រយៈពេល ខ្លី - វែង តាមគំរោង របស់ក្រសួង សំរាប់ មន្ត្រីរាជការក្នុងក្របខ័ណ្ឌ .

-ក្តាប់សភាពការណ៍រួមមន្ត្រីរាជការក្នុងក្រសួង ទិសដៅការងាររបស់ក្រសួងតម្រូវការ ជាក់ស្តែងក្នុងការបណ្តុះបណ្តាល និងលើកផែនការបណ្តុះបណ្តាល .

-ធ្វើផែនការសិក្សា ខ្លឹមសារសិក្សា កម្មវិធីសិក្សា កម្មវិធីទស្សនកិច្ច សិក្សា គ្រប់គ្រង វគ្គសិក្សា .

-ធ្វើរបាយការណ៍សរុប និងវាយតម្លៃការសិក្សាតាមវគ្គនីមួយ ៗ

៤-ការិយាល័យ គ្រប់គ្រងឯកសារ :

-ស្រាវជ្រាវ និងប្រមូលផ្តុំឯកសារ ពត៌មានគ្រប់ប្រភេទ ដែលពាក់ព័ន្ធដល់ការធ្វើ វិក្រឹត្យការ និងសុក្រឹតការ

-រក្សា និងតំកល់ទុក សំណុំឯកសារ សៀវភៅសិក្សាផ្សេង ៗ

-ផលិតឯកសារសិក្សាចាំបាច់ .

៣-ការិយាល័យ គរុកោសល្យ :

-អនុវត្តកម្មវិធីសិក្សាតាមជំនាញនីមួយៗ និង រិះរកវិធីសាស្ត្រអនុវត្តកម្មវិធីសិក្សា អោយមានប្រសិទ្ធភាព .

-ទំនាក់ទំនង និងសហការជាមួយគ្រប់អង្គភាពចំណុះក្រសួង ដើម្បីស្រាវជ្រាវវិធី សាស្ត្រ និងចិត្តសាស្ត្របង្រៀនអោយបានចំទិសដៅ .

**ប្រការ ៥.-**

សាលាបណ្ដុះបណ្ដាលក្របខ័ណ្ឌវប្បធម៌ អនុវត្តរបបហិរញ្ញវត្ថុបុព្វហេតុរដ្ឋបាលសាធារណៈ ។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុអគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាយកសាលាបណ្ដុះបណ្ដាលក្របខ័ណ្ឌវប្បធម៌ គ្រឹះស្ថានសាធារណៈ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត - ក្រុង និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**ចម្លងជូន**

- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

  "ដើម្បីជូនជ្រាបជាពត៌មាន"
- -ដូចប្រការ ៦
- -ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...១៥៧..... ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៧

**អង្គភាពលេខ សាលាបណ្តុះបណ្តាលក្រុមចំណូលប្បធម៌**

